# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជតក
ដាក់ទៅ : អង្គជំនុំជម្រះតុលាការកំពូល
ថ្ងៃដាក់ : ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Apr-2013, 11:48
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំការបញ្ជាប់ជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូង ឲ្យចេញសេចក្តីសម្រេចដែលមានសម្អាងហេតុស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រិម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele MUMBA

**ចម្លងជូន:**
សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន១០៤, ១០៥, ១០៦(២) និង ១០៧ នៃវិធានផ្ទៃក្នុង (“វិធាន”)[1] សហព្រះរាជអាជ្ញាដាក់សំណើនេះ (“សំណើ”) សុំឲ្យអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”)[2] បង្គាប់ទៅអង្គជំនុំជម្រះសាលាដំបូង ទុកជាកិច្ចការមួយបន្ទាន់បំផុត ឲ្យផ្តល់សេចក្តីសម្រេចដែលមានសំអាងហេតុចំពោះសេចក្តីសម្រេចផ្ទាល់មាត់ដោយសង្ខេបរបស់ខ្លួន ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ (“សេចក្តីសម្រេចដែលរងការជំទាស់”)[3]។ ជាសង្ខេប សហព្រះរាជអាជ្ញា មានទឡ្ហីករណ៍ចំនួនពីរចំពោះសំណើនេះ។

២. **ទីមួយ** សំណើនេះអាចទទួលយកបានបើតាមការអនុវត្តយុត្តាធិការដែលមានជាប់មកជាមួយស្រាប់របស់អង្គជំនុំជម្រះ ទៅលើការបកស្រាយនៃសេចក្តីសម្រេចពីមុនរបស់ខ្លួន ចំពោះមោឃភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ (“សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី”)[4] និងតម្រូវការនៃការធានាចំពោះការគ្រប់គ្រងយុត្តិធម៌ឲ្យបានល្អ ឬផ្ទុយពីនេះ សំណើអាចទទួលយកបានផ្អែកលើវិធាន ១០៤(៤)(ក) (**វាក្យខណ្ឌ III**)។

៣. **ទីពីរ** ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្តល់ជូននូវសម្អាងហេតុណាមួយ ទោះជាយ៉ាងណាក៏ដោយសម្រាប់សេចក្តីសម្រេចដែលរងការជំទាស់នេះលើសពីរយៈពេល២១ថ្ងៃ គឺមិនសមហេតុផលទេនៅក្នុងកាលៈទេសៈ និងឱកាសទាំងនេះដែលមានការខូចខាតយ៉ាងខ្លាំងចំពោះសហព្រះរាជអាជ្ញា និងភាគីដទៃទៀត (**វាក្យខណ្ឌ IV**)។ ភាគីទាំងអស់ត្រូវបានគេបដិសេធនូវលទ្ធភាពទទួលទាន់ពេលវេលានូវគោលជំហរផ្លូវច្បាប់របស់ពួកគេរៀងៗខ្លួន ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ ដូច្នេះ សិទ្ធិប្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងរបស់ភាគីដទៃទៀត ក៏ត្រូវបានគេធ្វើឲ្យទៅជាគ្មានន័យ ឬត្រូវធ្វើឡើងដោយឆាប់ៗ ដោយសារៈ (i) ពេលវេលាកាន់តែខ្លីទៅៗបណ្តាលមកពីសវនាការនេះត្រូវបានបំបែកដែលធ្វើឲ្យមានបុរេនិវត្តិ៍យនៅពេលបញ្ចប់។ (ii) ក្របខណ្ឌពេលវេលារយៈពេលបីខែដែលបានផ្តល់ដោយវិធាន១០៨ (*៤ស្ទួន*)សម្រាប់សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ និង

---

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨), ដែលបានកែសម្រួលនៅថ្ងៃទី៣ សីហា ២០១១ (“វិធាន”)។

[2] E163/5 សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន, ៨ តុលា ២០១២ (“សេចក្តីសម្រេចដែលរងការជំទាស់”)។

[3] E1/176.1 ប្រតិចារឹក, ២៩ មីនា ២០១៣, ទំព័រទី២ បន្ទាត់ទី២១ ដល់ទំព័រទី៤ បន្ទាត់ទី១៧។

[4] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់សហព្រះរាជអាជ្ញាប្រឆាំងនឹង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ៨ កុម្ភៈ ២០១៣ (“សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី”)។

(iii) ជាលទ្ធផល ការរំពឹងទុកចំពោះការអនុវត្តឲ្យមានប្រសិទ្ធភាពចំពោះដំណោះស្រាយណាមួយដែលអាចផ្តល់ជូនទៅលើបណ្តឹងសាទុក្ខភ្លាមៗនោះ។

## II. ប្រវត្តិនីតិវិធី

៤. នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះបានរកឃើញថា បណ្តឹងសាទុក្ខអាចទទួលយកបានដោយផ្អែកលើទឡ្ហីករណ៍ថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងមានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីតាមវិធាន១០៤(៤)(ក)។ អង្គជំនុំជម្រះតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិចារណាអំពីការបំបែកដំណើរការនីតិវិធីនៃសំណុំរឿង០០២ ឡើងវិញ ដើម្បីផ្តល់នូវ "ផែនការច្បាស់លាស់ជាក់ស្តែងមួយសម្រាប់ការវិនិច្ឆ័យសេចក្តីលើបទចោទទាំងមូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[5]។ អង្គជំនុំជម្រះបានសម្រេចថា៖ ប្រសិនបើ "នៅពេលប្រឈមមុខនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទចេះតែដុនដាបទៅ[...] ត្រូវតែផ្តល់យុត្តិធម៌ឲ្យបានប្រសើរជាង តាមរយៈការបញ្ចប់ [សំណុំរឿង០០២] ជាមួយនឹងការចេញសាលក្រម [...] យ៉ាងហោចណាស់ លើការជំនុំជម្រះតូចមួយនៃផ្នែកខ្លះៗនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ថាអង្គជំនុំជម្រះសាលាដំបូងគប្បី "បញ្ជាក់ច្បាស់លាស់ និងផ្តល់ការពិចារណាឲ្យបានសមស្របទៅលើការតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅជាការជំនុំជម្រះតូចជាងនេះ"[6]។

៥. ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយដោយកំណត់ការយល់ឃើញរបស់ខ្លួន ស្តីពីសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធីថា៖ "ផលវិបាកភ្លាមៗនៃសេចក្តីសម្រេចរបស់ អជតក នេះគឺថា សំណុំរឿង០០២ មិនត្រូវបានកំណត់វិសាលភាពទៀតទេ ហើយអង្គជំនុំជម្រះសាលាដំបូង បច្ចុប្បន្នមិនអាចដំណើរការចេញសាលក្រមលើសំណុំរឿង០០២ បានទេ រហូតទាល់តែផ្នែកអង្គហេតុ និងបទចោទចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ទាំងមូលត្រូវបានជម្រះ"[7]។ អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមទៀតថាខ្លួន "នឹងចេញសេចក្តីសម្រេចដោយមានសម្អាងហេតុពេញលេញមួយ ទាក់ទិននឹងវិសាលភាពនៃសំណុំរឿង០០២/០១ ឲ្យបានឆាប់រហ័ស

---

[5] E163/5/1/13 *ក្នុងឯកសារដដែលដូចខាងលើ*, កថាខណ្ឌទី៥០។

[6] E163/5/1/13 *ដដែលដូចខាងលើ* ។

[7] E163/5/1/13/1 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការណែនាំដល់ភាគីនានា ដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿង ០០២/១ (ឯកសារ E163/5/1/13), ១២ កុម្ភៈ ២០១៣ ត្រង់កថាខណ្ឌ ២។

បន្ទាប់ពី [សវនាការផ្ទាល់មាត់ដែលបានកំណត់ពេលរួច] ដោយពិចារណាទៅលើសារណារបស់ភាគី និងគោលការណ៍នានា ដែលមាននៅក្នុងសេចក្ដីសម្រេចរបស់ អជតក"[8]។

៦. នៅថ្ងៃទី១៤-១៥ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការផ្ទាល់មាត់ ស្ដីពីបញ្ហានៃការបំបែកកិច្ចដំណើរការនីតិវិធីនេះ ដោយអញ្ជើញឱ្យមានការដាក់សេចក្ដីសន្និដ្ឋានផ្សេងៗរបស់ភាគី ទាក់ទងនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងពេលអនាគត ដោយផ្អែកទៅលើមូលដ្ឋាននៃសំណួរជាក់លាក់នានា[9]។

៧. នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានប្រកាសនៅក្នុងតុលាការថា៖ "ចំពោះសម្អាងហេតុដែលនឹងគូសបញ្ជាក់អំពី សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់ខ្លួននោះ អង្គជំនុំជម្រះសាលាដំបូងសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ដោយអនុលោមតាមវិធាន៨៩*ស្ទួនពីរ* ដោយការកំណត់វិសាលភាពនៃសំណុំរឿង ០០២/០១ ចំពោះបទចោទនានាដែលជាប់ទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំ ដំណាក់កាលទី១ និងទី២ និងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ"[10]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់ផងដែរថា សម្អាងហេតុសម្រាប់សេចក្ដីសម្រេចនោះ នឹងមានជាលាយលក្ខណ៍អក្សរជាបន្តជាបន្ទាប់ "ក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន"[11]។ នៅថ្ងៃដដែល សហព្រះរាជអាជ្ញាបានធ្វើការប្រាស្រ័យទាក់ទងជាមួយមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ដោយស្នើសុំឱ្យគាត់បញ្ជាក់ថានៅពេលណា អង្គជំនុំជម្រះសាលាដំបូងនឹងចេញសម្អាងហេតុអំពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២[12]។ ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់បានឆ្លើយតបថា សម្អាងហេតុនឹងផ្ដល់ជូន "ក្នុងពេលឆាប់ៗនេះតាមដែលអាចធ្វើទៅបាន" ដោយមានការសង្កេតថា ដំណើរការបកប្រែ និងការកែសម្រួល ព្រមទាំងភាពមិនអាចរកបានជាសក្ដានុពលនៃបុគ្គលជាតិ ជាការលំបាកក្នុងការប៉ាន់ស្មានថានៅពេលណាទើបសេចក្ដីសម្រេចដែលមានសម្អាងហេតុនឹងអាចចេញបាន[13]។

៨. ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានដាក់សំណើមួយដោយស្នើឱ្យមានការបញ្ជាក់បំភ្លឺពីភាពអាចរកបាននៃសម្អាងហេតុជាលាយលក្ខណ៍អក្សរ ចំពោះកថាខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលបានកែសម្រួលឡើងវិញ ត្រឹមថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ - ឬដោយសារធនធាននៃការបកប្រែមិនទាន់អាចរកបានក្នុងពេលចូលឆ្នាំខ្មែរ - សូមស្នើឱ្យផ្ដល់សម្អាង

---

[8] E163/5/1/13/1 *ដដែលដូចខាងលើ*, កថាខណ្ឌទី៥។

[9] E163/5/1/13/1 *ដដែលដូចខាងលើ*។

[10] E1/176.1 ប្រតិចារឹក,កំណត់សម្គាល់ខាងដើម ៣, ត្រង់ទំព័រទី៤, បន្ទាត់ទី១៣ ដល់ ១៧។

[11] E1/176.1 *ដដែលដូចខាងលើ* ទំព័រទី២ បន្ទាត់ទី២១ ដល់ទំព័រទី៤ បន្ទាត់ទី១៧។

[12] អ៊ីម៉ែលពីសហព្រះរាជអាជ្ញារងអន្តរជាតិ ផ្ញើជូនមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់, ២៩ មីនា ២០១៣។

[13] អ៊ីម៉ែលពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ផ្ញើជូនគូភាគី, ២៩ មីនា ២០១៣។

ហេតុលាយលក្ខណ៍អក្សរមកភាគី តែមួយភាសាផ្លូវការសិន ដោយគិតត្រឹមកាលបរិច្ឆេទនេះ[14]។ អង្គជំនុំជម្រះសាលាដំបូងពុំបានឆ្លើយតបទៅនឹងសំណើសុំនេះទេ។

៩. ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៣ នៅមុនពេលចាប់ផ្តើមការផ្តល់សក្ខីកម្មរបស់សាក្សីក្នុងសំណុំរឿង ០០២/០១ សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង បញ្ជាក់អះអាងអំពីកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ដែលកើតចេញពីសេចក្តីសម្រេចនេះថាតើ វាដូចគ្នានឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដើមដែរឬទេ[15]។ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ បានឆ្លើយតបនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ ដោយបញ្ជាក់អះអាងថា វិសាលភាពនៃការបំបែកកិច្ចដំណើរការនីតិវិធី ពិតណាស់គឺដូចគ្នានឹងអ្វីដែលបានកំណត់ពីមុន[16]។

១០. ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញារង បានស្នើបញ្ជាក់ពីបច្ចុប្បន្នភាពនៃពេលវេលានៃការដាក់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនេះទៅក្នុងសំណុំរឿង[17]។ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ បានឆ្លើយតបនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣ បញ្ជាក់ថាបច្ចុប្បន្នភាព "មិនអាច" ផ្តល់ជូនបានទេ "ក្រៅពីអាចនិយាយបានថា វាមិនយូរពេកនោះឡើយ"[18]។

## III. យុត្តាធិការ និង ភាពអាចទទួលយកបាន

### ក. សំណើនេះអាចទទួលយកបានដោយការអនុវត្តនូវយុត្តាធិការ ដែលមានជាប់មកជាមួយស្រាប់

១១. ក្នុងនាមជាស្ថាប័នតុលាការសម្រាប់បណ្តឹងសាទុក្ខមួយ អង្គជំនុំជម្រះនេះមានយុត្តាធិការជាប់មកជាមួយស្រាប់ទៅលើបញ្ហានានាដែលមានវិសាលភាពទូលំទូលាយ ដែលពាក់ព័ន្ធទៅនឹងការកំណត់សម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ។ វិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់ស្តីពីការប្រគល់អំណាចឲ្យក្នុងការបើកធ្វើសវនាការស្តាប់ចម្លើយដោយផ្ទាល់មាត់[19] ដើម្បីទទួលយកនូវភស្តុតាងបន្ថែម[20] ហើយនិងដើម្បីធ្វើការកែប្រែបទល្មើសដែលបានចោទប្រកាន់[21]។

---

[14] E264/4 សំណើរបស់សហព្រះរាជអាជ្ញា សុំការបញ្ជាក់អំពីភាពអាចរកបាននៃសម្អាងហេតុជាលាយលក្ខណ៍អក្សរនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលបានកែសម្រួលឡើងវិញ, ៥ មេសា ២០១៣។

[15] អ៊ីម៉ែលពីសហព្រះរាជអាជ្ញារង ផ្ញើជូនគូភាគី, ៧ មេសា ២០១៣។

[16] អ៊ីម៉ែលពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ផ្ញើជូនគូភាគី, ៨ មេសា ២០១៣។

[17] អ៊ីម៉ែលពីសហព្រះរាជអាជ្ញារង ផ្ញើជូនគូភាគី, ១៨ មេសា ២០១៣។

[18] អ៊ីម៉ែលពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ ផ្ញើជូនគូភាគី, ១៩ មេសា ២០១៣។

[19] វិធាន១០៩ នៃវិធានផ្ទៃក្នុង។

[20] វិធាន១០៨(៧) នៃវិធានផ្ទៃក្នុង។

[21] វិធាន១១០(១) នៃវិធានផ្ទៃក្នុង ដែលចែងថា៖ "គ្រប់ករណី..."គឺបង្កប់ន័យថា នៅពេលធ្វើការបកស្រាយនូវវិធាន១១០(១)ថា សិទ្ធិនេះគឺលាតសន្ធឹងទៅដល់ទាំង"បញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹង[អំពីបណ្តឹងសាទុក្ខ] *ផង ឬទៅក្នុងបណ្តឹងសាទុក្ខភ្លាមៗផង*"។

១២. ប្រព័ន្ធច្បាប់ក្នុងស្រុកនានា ជាសំខាន់ប្រព័ន្ធច្បាប់ទាំងឡាយនៅក្នុងទំនៀមទម្លាប់របស់ប្រព័ន្ធច្បាប់អង់ហ្គ្លេសាក់សុង(Common Law) បានទទួលស្គាល់កាន់តែទូលំទូលាយជាងនេះទៀតអំពីយុត្តាធិការដែលមានជាប់មកជាមួយស្រាប់របស់តុលាការបណ្ដឹងសាទុក្ខនានា ដែលរួមទាំងសិទ្ធិអំណាចក្នុងការបើកធ្វើជាថ្មីឡើងវិញលើបណ្ដឹងសាទុក្ខនានាដែលបានបំពេញរួចចប់សព្វគ្រប់ហើយផង។ តុលាការបណ្ដឹងសាទុក្ខនានានៅប្រទេសអង់គ្លេស និងវេលហ្ស៍[22], នូវ៉ែលហ្សេឡង់[23] និង ហុងកុង (Hong Kong SAR)[24] សុទ្ធតែបានបញ្ជាក់ ឬផ្ដល់ការយល់ព្រមលើទស្សនៈថា តុលាការបណ្ដឹងសាទុក្ខទាំងឡាយសុទ្ធតែមានបង្កប់នូវសិទ្ធិអំណាចសម្រាប់ធ្វើអ្វីៗដែលចាំបាច់ដើម្បីសម្រេចឲ្យបាននូវគោលដៅដ៏សំខាន់ពីរក្នុងការកែតម្រូវនូវសេចក្ដីសម្រេចទាំងឡាយដែលខុស និងធានានូវភាពជឿទុកចិត្តរបស់សាធារណជននៅក្នុងការគ្រប់គ្រងយុត្តិធម៌ ដែលនៅក្នុងនោះរួមទាំងចំណាត់ការពិសេសឲ្យបើកធ្វើកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីជាថ្មីឡើងវិញ ដែលបានធ្វើការកំណត់សម្រេចរួចហើយផង ក្នុងករណីបើសិនជាត្រូវបាន "រកឃើញយ៉ាងច្បាស់ថាភាពអយុត្តិធម៌ណាមួយបានកើតឡើង ហើយពុំមានដំណោះស្រាយតាមផ្លូវច្បាប់ណាមួយជាជំនួសដ៏មានប្រសិទ្ធភាពទេនោះ"[25]។ នីតិកម្មដែលសម្រាប់គ្រប់គ្រងកិច្ចដំណើរការរបស់តុលាការបណ្ដឹងសាទុក្ខនានា នៅក្នុងប្រទេសកាណាដា[26] និងប្រទេសកេនយ៉ា[27] ក្នុងចំណោមបណ្ដាប្រទេសជាច្រើនផ្សេងទៀត បានទទួលស្គាល់នូវពាក្យពេចន៍ដ៏ទូលំទូលាយថា តុលាការទាំងឡាយបែបនេះ មានយុត្តាធិការទៅលើគ្រប់បញ្ហាទាំងអស់ដែលចាំបាច់ ឬជាការចៃដន្យដើម្បីធ្វើសវនាការ ឬការកំណត់សម្រេចលើបណ្ដឹងសាទុក្ខណាមួយ។

១៣. នៅក្នុងកំរិតអន្តរជាតិ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានសម្រេចថា យុត្តាធិការដែលមានជាប់មកជាមួយស្រាប់បែបនេះ រួមមាន ប៉ុន្តែមិនកំរិតត្រឹមតែសិទ្ធិអំណាចក្នុងការកំណត់សម្រេចលើវិសាលភាពនៃយុត្តាធិការរបស់អង្គជំនុំជម្រះខ្លួនឯងផ្ទាល់នោះទេ ("សមត្ថកិច្ចនៃសមត្ថកិច្ច)[28]។ តុលាការយុត្តិធម៌អន្តរជាតិ[29], តុលាការដែលប្រទេសអៀរ៉ង់ និងសហរដ្ឋអាមេរិក

---

[22] ករណីរឿងក្ដីរបស់ *Taylor& Anor ទល់នឹង Lawrence & Anor* [២០០៣], សំណុំរឿងលេខ QB 528, តុលាការកំពូល (សាលាឧទ្ធរណ៍ (ផ្នែករដ្ឋប្បវេណី) ចុះថ្ងៃទី០៤ កុម្ភៈ ២០០២។

[23] ករណីរឿងក្ដីរបស់ *R ទល់នឹង Smith* [២០០៣] សំណុំរឿងលេខ 3 NZLR 617 (សាលាឧទ្ធរណ៍) ចុះថ្ងៃទី១៩ ធ្នូ ឆ្នាំ២០០២។

[24] ករណីរឿងក្ដីរបស់ *Hong Kong SAR ទល់នឹង Tin"s Label Factory* [២០០៩] ផ្នែកទី៩, សំណុំរឿងលេខ 8 [សាលាឧទ្ធរណ៍ចុងក្រោយ] ត្រង់កថាខណ្ឌទី៥៣-៥៦, ចុះថ្ងៃទី ៥ ធ្នូ ២០០៨។

[25] *ករណីរឿងក្ដីរបស់ Taylor ទល់នឹង Lawrence*, កំណត់សម្គាល់ខាងដើម ២២,កថាខណ្ឌ ៥៥។

[26] ច្បាប់លក្ខន្តិកៈរបស់សាលាឧទ្ធរណ៍, *លក្ខន្តិកៈនៃ Saskatchewan [2000]*, ជំពូក. Ch. C-42.1 (ប្រទេសកាណាដា)។

[27] *ច្បាប់ស្ដីពីយុត្តាធិការសំរាប់បណ្ដឹងសាទុក្ខ* [2009] Ch. 9, s. 3(2) (ប្រទេសកេនយ៉ា)។

[28] *ករណីរឿងក្ដីរបស់ រដ្ឋអាជ្ញា ទល់នឹង Dusko Tadić*, សំណុំរឿងលេខ IT-94-1, សេចក្ដីសំរេចលើញត្តិរបស់មេធាវីការពារក្ដីសុំប្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំស្ដីពីយុត្តាធិការ, ចុះថ្ងៃទី២ តុលា ១៩៩៥ ត្រង់កថាខណ្ឌទី១៧ -១៨។

[29] លក្ខន្តិកៈរបស់តុលាការយយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី២៤ តុលា ១៩៤៥, មាត្រា៦០។ វិធានផ្ទៃក្នុងរបស់តុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី០១ កក្កដា ១៩៧៨, មាត្រា៩៨។

ទាមទារ[30], អតីតតុលាការរដ្ឋបាលនៃអង្គការសហប្រជាជាតិ[31] តុលាការសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប[32], តុលាការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិកាំង[33] និងតុលាការទ្វីបអាហ្វ្រិកស្តីពីសទ្ធិមនុស្សនិងសិទ្ធិប្រជាពលរដ្ឋ[34] សុទ្ធតែបានទទួលនូវយុត្តាធិការដែលមានជាប់មកជាមួយស្រាប់ ឬយុត្តាធិការដោយផ្អែកលើមូលដ្ឋាននៃសន្និសញ្ញា ដើម្បីធ្វើការបកស្រាយអំពីសេចក្តីសម្រេចនានារបស់ខ្លួន។ គឺដោយផ្អែកលើមូលដ្ឋានច្បាប់ដូចគ្នានេះ ហើយដែលប្រទេសកម្ពុជា ក្នុងពេលថ្មីៗនេះបានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិនៅក្នុងរឿងក្តីស្តីពី *ប្រាសាទព្រះវិហារ*[35]។

១៤. នៅក្នុងករណីរឿងក្តីមុននេះរបស់ *Ringeisen* (ឆ្នាំ១៩៧៣) តុលាការសិទ្ធិមុស្សរបស់ទ្វីបអឺរ៉ុបបានបញ្ជាក់ថាដំណោះស្រាយតាមផ្លូវច្បាប់ ដើម្បីធ្វើការបកស្រាយនោះគឺការអនុវត្តនូវយុត្តាធិការមានជាប់មកជាមួយស្រាប់ ដែលខុសគ្នាពីដំណោះស្រាយតាមផ្លូវច្បាប់តាមរយៈការប្តឹងសាទុក្ខ៖

> *សំណើសុំដើម្បីឲ្យធ្វើការបកស្រាយណាមួយ គឺវាមិនបង្កើតបានតាមបែបណាមួយ ទៅជាបណ្តឹងសាទុក្ខមួយបែបនេះដោយសារតែសំណើនោះបានជូនទៅតុលាការផ្ទាល់តែម្តង។ ក្នុងការពិចារណាលើសំណើនេះ គឺតុលាការបានអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនដែលមានជាប់មកជាមួយស្រាប់ ៖ តុលាការមិនធ្វើអ្វីតទៅទៀតក្រៅពីបញ្ជាក់បំភ្លឺអំពីនិយមន័យ និងវិសាលភាពដែលខ្លួនមានបំណងចង់ផ្តល់ឲ្យទៅដល់សេចក្តីសម្រេចមួយកាលពីមុន ដែលបានចេញដោយការគិតគូរពិភាក្សារបស់ខ្លួនផ្ទាល់ដែលកំណត់បញ្ជាក់ថា បើសិនជាត្រូវការចាំបាច់តាមដូចដែលខ្លួនបានសម្រេចដែលមានអំណាចចាប់បង្ខំឲ្យអនុវត្ត។ អាស្រ័យហេតុនេះសិទ្ធិអំណាចបែបនេះ គឺមិនមានផ្លូវថាមិនអាចផ្ទុះផ្ទារគ្នាបានជាមួយនឹងមាត្រា៥២ ឬ ជាងនេះទៅទៀតជាមួយនឹងមាត្រា៥៤ ដែលធ្វើឲ្យគណៈរដ្ឋមន្ត្រី ដែលជាអ្នកទទួលខុសត្រូវក្នុងការត្រួតមើលលើការអនុវត្តដីការបស់តុលាការ*[36]។

---

30 សូមអាន ឧទាហរណ៍ដូចជា *ករណីរឿងក្តីរបស់ Ford Aerospace and Communications Corporation* (១៩៨៦), សំណុំរឿងលេខ12 Iran-US CTR 305។

31 ករណីរឿងក្តីរបស់ *Crawford* និងគូកន (១៩៥៥) UNAT 61, ត្រង់ទំព័រ 355។ ករណីរឿងក្តីរបស់ *Khalil* (២០០០) UNAT *973 សាលក្រម,* ត្រង់ទំព័រ៣។

32 សូមអាន ឧទាហរណ៍ដូចជា *ករណីរឿងក្តីរបស់ Ringeisen ទល់នឹង ប្រទេស Austria* (ការបកស្រាយ), ពាក្យសុំលេខ 2614/65, សាលក្រមចុះថ្ងៃទី, មិថុនា ១៩៧៣។

33 អនុសញ្ញាអាមេរិក ស្តីពីសិទ្ធិមនុស្ស, មាត្រា៦៧។ វិធានស្តីពីនីតិវិធីរបស់ IACHR, មាត្រា៥៩។ សូមមើល ឧទាហរណ៍ *រឿងក្តី ក្មេងស្រីយៀន និងបូស៊ីកូ ទល់នឹង សាធារណៈរដ្ឋដូមីនីកែន, សាលក្រម,* ២៣ វិច្ឆិកា ២០០៦។

34 ពិធីសារនៃធម្មនុញ្ញអាហ្វ្រិក ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអំពីការបង្កើតតុលាការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន, មាត្រា ២៨(៤)។

35 សូមមើល *សំណើសុំបកស្រាយសាលក្រម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ ក្នុងករណីរឿងក្តីប្រាសាទព្រះវិហារ (កម្ពុជា ទល់នឹងថៃ)* (កម្ពុជា ទល់នឹងថៃ), *ពាក្យសុំរបស់ព្រះរាជាណាចក្រកម្ពុជា,* ២៨ មេសា ២០១១ ត្រង់កថាខណ្ឌទី១។ សេចក្តីប្រកាសព័ត៌មានរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) លេខ ២០១២/៣៦ "តុលាការនឹងបើកសវនាការជាសាធារណៈ ចាប់ពីថ្ងៃទី១៥ ដល់១៩ ខែមេសា ឆ្នាំ២០១៣", ២៩ វិច្ឆិកា ២០១២។

36 *Ringeisen ទល់នឹង ប្រទេសអូទ្រីស* (ការបកស្រាយ) ពាក្យសុំលេខ 2614/65, *សាលក្រម,* ២៣ មិថុនា ១៩៧៣ ត្រង់កថាខណ្ឌទី១៣។

១៥. ហេតុដូចនេះ អង្គជំនុំជម្រះអាចចាត់ទុកដោយត្រឹមត្រូវថាការទទួលយកនូវបណ្តឹងដោយផ្អែកលើមូលដ្ឋានច្បាប់ដូចគ្នាតែមួយថាជា ការសម្រេចបញ្ចប់របស់ខ្លួននៅក្នុងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី ជាជាងថាជាបណ្តឹងសាទុក្ខថ្មីមួយ ដែលមានសិទ្ធិធ្វើ បណ្តឹងដោយខ្លួនឯង។ សំណើនេះគឺជាប់ពាក់ព័ន្ធនឹងមធ្យោបាយ និងក្របខណ្ឌពេលវេលាសម្រាប់អនុវត្តនូវសេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី និងការផ្តល់ជូនអំពីមូលហេតុគ្រប់គ្រាន់សម្រាប់ការធ្វើសេចក្តីសម្រេចដែលរងការជំទាស់នេះ ដែលបញ្ហាទាំងពីរនេះបានលើកឡើងដោយផ្ទាល់ដោយអង្គជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធី[37]។

១៦. អាស្រ័យដោយមូលហេតុខាងលើនេះ សហព្រះរាជអាជ្ញាស្នើដោយគោរពថា សូមឱ្យទទួលយកនូវសំណើនេះនៅចំពោះមុខអង្គជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃយុត្តាធិការដែលមានជាប់មកជាមួយស្រាប់របស់អង្គជំនុំជម្រះនេះ ថាជាតុលាការបណ្តឹងសាទុក្ខមួយដែលស្ថិតនៅកំពូលខ្ពស់ជាងគេបំផុតទៅលើការបកស្រាយអំពីសេចក្តីសម្រេចនានារបស់ខ្លួន ជាពិសេសទៅលើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣។

## ខ. ជាជម្រើសម្យ៉ាងទៀត សំណើនេះអាចទទួលយកបាន ដោយអនុលោមតាម វិធាន១០៤(៤)(ក) នៃវិធានផ្ទៃក្នុង

១៧. ដូចដែលអង្គជំនុំជម្រះនេះធ្លាប់បានសម្រេចកន្លងមកហើយថា ខ្លួនមានយុត្តាធិការក្នុងការសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗអំពី "កំហុសដែលគេអាចយល់បាននៅក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យខូចខាតដល់សិទ្ធិរបស់ដើមបណ្តឹងសាទុក្ខ"[38]។ បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា អំពីសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានសម្រេចថា អាចទទួលយកបានដោយអនុលោមតាមវិធាន១០៤(៤)(ក)នៃវិធានផ្ទៃក្នុង ពីព្រោះវិធាននោះ "ធានាថាមានទីកន្លែងសម្រាប់ប្តឹងសាទុក្ខ បើសិនជាកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់ដោយពុំបានឈានទៅដល់ការចេញសាលក្រមមួយ ហើយដែលហេតុដូចនេះ ពុំមានឱកាសក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចនេះ" ហើយ "ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងលេខ ០០២ នៅក្នុងការជំនុំជម្រះក្តីដាច់តែឯង គឺជៀសមិនរួចពីស្ថានភាពដំណើរការនីតិវិធីដែល

[37] E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី, កំណត់សំគាល់*ខាងដើម* លេខ៤ ត្រង់កថាខណ្ឌទី៤១, ៥០។

[38] E163/5/1/13 *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី១៣។

ទាក់ទងទៅនឹងបទចោទប្រកាន់ផ្សេងៗដែលស្ថិតនៅក្រៅពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១ ត្រូវបានផ្អាកដោយប្រសិទ្ធភាព”[39]។

១៨. អង្គជំនុំជម្រះនេះបានរំលឹកឡើងវិញថា “សេចក្តីសម្រេចណាមួយក៏ដោយរបស់អង្គជំនុំជម្រះសាលាដំបូង”-ទោះបីជាលើខ្លឹមសារ ឬនីតិវិធី- ដែលចាត់ចូលនៅក្នុងវិសាលភាពនៃប្រភេទណាមួយក្នុងចំណោមប្រភេទទាំងបួនដែលស្ថិតនៅក្រោមវិធាន១០៤(៤)នៃវិធានផ្ទៃក្នុង គឺជាប្រធានបទនៃការធ្វើបណ្តឹងសាទុក្ខភ្លាមៗ ហើយដែលអាចត្រឡប់បញ្ច្រាស់មកវិញបាន បើសិនជានៅក្នុងបណ្តឹងសាទុក្ខភ្លាមៗនេះ *ក្នុងចំណោមអ្វីៗជាច្រើនទៀត* មានកំហុសដែលគេអាចយល់ដឹងបាននៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង បានបណ្តាលឲ្យមានការខូចខាតដល់សិទ្ធិ ឬផលប្រយោជន៍របស់ដើមបណ្តឹងសាទុក្ខ”[40]។ ដូចដែលបានចែងខាងក្រោមនេះ ការអនុវត្តរបស់សាលាដំបូងនូវឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីចេញសេចក្តីសម្រេចមួយលើសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដោយផ្ទាល់មាត់ ដោយពុំមានការវែកញែកហេតុផល ហើយដែលបន្ទាប់មកទៀត ពន្យារពេលនៅក្នុងការចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមួយដែលមិនសមហេតុផល នៅក្រោមកាលៈទេសៈផ្សេងៗ ជាពិសេសដោយសារតែ “សារៈសំខាន់នៃរាល់បញ្ហាទាំងអស់ជារួមដែលស្ថិតនៅចំពោះមុខ”[41] គឺគ្រាន់តែជាការអនុវត្តឆន្ទានុសិទ្ធិមួយដែលនាំឲ្យមានការខូចខាតដ៏ធ្ងន់ធ្ងរដល់សិទ្ធិ ឬផលប្រយោជន៍របស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។

## IV. **អង្គសេចក្តី**

### ក. លក្ខខណ្ឌគតិយុត្តិនៃសម្អាងហេតុនានាជាលាយលក្ខណ៍អក្សរមិនធានាថា ត្រូវតែមានសម្អាងហេតុវែងជាពិសេស ឬសម្អាងហេតុដែលស្មុគស្មាញនោះទេ

### (I) ច្បាប់ដែលពាក់ព័ន្ធ

១៩. ច្បាប់ជាធរមានស្តីពីសេចក្តីសម្រេចតាមផ្លូវតុលាការដែលមានសម្អាងហេតុ បានចែងយ៉ាងច្បាស់ថា ស្ថាប័នតុលាការមានភារកិច្ចចេញសេចក្តីសម្រេចដែល *ទម្រង់*របស់វាឆ្លុះបញ្ចាំងពីវិធានការគតិយុត្តដែលមានលក្ខណៈអាជ្ញាបញ្ញា ហើយ*ខ្លឹមសារ*របស់វាត្រូវមានសម្អាងហេតុពេញលេញ។ ដូចដែលអង្គជំនុំជម្រះនេះបានផ្តល់សេចក្តីសង្កេតនៅក្នុងបណ្តឹងសាទុក្ខថ្មីមួយរបស់មេធាវីការពារក្តីថា៖

> [...] *ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងក្នុងឱកាសខុសៗគ្នាថា រាល់សេចក្តីសម្រេចតាមផ្លូវតុលាការទាំងអស់ មិនថាជាសេចក្តីសម្រេចផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរឡើយ ត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់សម្អាងហេតុគ្រប់គ្រាន់ ចំពោះសេចក្តីសម្រេចទាំងនោះ ដែលជាផលនៃការគោរពសិទ្ធិ*

[39] E163/5/1/13 *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី២២។

[40] E163/5/1/13 *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី៣៩។

[41] E163/5/1/13 *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី៣៦។

> *របស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាការពិតណាស់ សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសម្អាងហេតុពេញលេញ គឺជាផ្នែកមួយនៃសិទ្ធិទទួលបានការជំនុំជម្រះ[42] ។*

សេចក្តីសម្រេចលើបណ្តឹងសាទុក្ខជំទាស់នឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបញ្ជាក់ជាថ្មី និងបំភ្លឺពីសេចក្តីសន្និដ្ឋានទាំងនេះ[43]។

២០. ស្រដៀងគ្នានេះដែរ លក្ខន្តិកៈនានាដែលគ្រប់គ្រងតុលាការ ICC , ICTY និង ICTR តម្រូវឲ្យមានយោបល់ដែលមានសម្អាងហេតុសម្រាប់សេចក្តីសម្រេចតាមផ្លូវតុលាការ[44]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា សេចក្តីសម្រេចមួយដែលមានសម្អាងហេតុជួយឲ្យធានាបាននូវគោលការណ៍សិទ្ធិមនុស្សជាសារវ័ន្ត ដែលគ្រប់គ្រងសិទ្ធិរបស់ចុងចោទក្នុងការទទួលបានសវនាការប្រកបដោយយុត្តិធម៌ និងសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍[45]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង "មានកាតព្វកិច្ចទូទៅមួយក្នុងការបញ្ចេញយោបល់ដែលមានសម្អាងហេតុ"[46] ដែលផ្តល់សម្អាងហេតុគ្រប់គ្រាន់សម្រាប់ការវាយតម្លៃរបស់ខ្លួន និង "ថ្លឹងថ្លែងឲ្យបានពេញលេញនូវរាល់កត្តាទាំងអស់"[47]។ "វិសាលភាពនៃការផ្តល់សម្អាងហេតុ [របស់អង្គជំនុំជម្រះ] នឹងផ្អែកទៅតាមកាលៈទេសៈនៃរឿងក្តី"[48]។ ទោះជាយ៉ាងណាក្តី ជាអប្បបរមា អង្គជំនុំជម្រះសាលាដំបូងត្រូវ "ផ្តល់សម្អាងហេតុដើម្បី

---

[42] ឯកសារ **E176/2/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ត្រង់កថាខណ្ឌ ២៥ (អត្ថបទដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[43] ឯកសារ **E163/5/1/13** សេចក្តីសម្រេចបណ្តឹងសាទុក្ខ, ជើងទំព័រ ៤ *ខាងលើ* ត្រង់កថាខណ្ឌ ៣០, ៣៦, ៤១, ៤៤។

[44] សូមមើល លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចុះថ្ងៃទី២៥ ឧសភា ១៩៩៣, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ 827, មាត្រា ២៣, លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ 955 ចុះថ្ងៃទី ០៨ វិច្ឆិកា ១៩៩៤, មាត្រា ២២ ; លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៧៤ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨។

[45] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ, មាត្រា ១៤, ឯកសារ 999 U.N.T.S. 171 (ថ្ងៃទី២៣ ខែ មិនា ឆ្នាំ១៩៧៦)។ សូមមើលផងដែរ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Momir Nikolić,* សំណុំរឿងលេខ IT-02-60/1-A, សាលដីកាលើបណ្តឹងឧទ្ធរណ៍ដែលផ្តន្ទាទោស (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០០៦ ត្រង់កថាខណ្ឌ ៩៦; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac,* និងជនផ្សេងទៀត, សំណុំរឿងលេខ IT-96-23 និង IT-96-23/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២, ត្រង់កថាខណ្ឌ ៤១។

[46] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Momir Nikolić,* សំណុំរឿងលេខ IT-02-60/1-A, សាលដីកាលើបណ្តឹងឧទ្ធរណ៍ដែលផ្តន្ទាទោស (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ ត្រង់កថាខណ្ឌ ៩៦។

[47] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac,* និងជនផ្សេងទៀត, សំណុំរឿងលេខ IT-96-23 និង IT-96-23/1-A, សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០២ ត្រង់កថាខណ្ឌ ៣២៤។

[48] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo,* សំណុំរឿងលេខ ICC-01/04-01/06 (OA 5), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ លោក Thomas Lubanga Dyilo ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើកទី១ ទៅលើសំណើរបស់អយ្យការ និងសំណើដែលបានកែប្រែសុំការកោសលុបតាមវិធាន ៨១" (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC), ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦ ត្រង់កថាខណ្ឌ ២០។

គាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនលើការពិចារណាលើអង្គសេចក្តីដែលពាក់ព័ន្ធ សម្រាប់សេចក្តីសម្រេចរបស់ខ្លួន”[49]។

### (II) **ឧទាហរណ៍**

២១. ដូចបានកត់សម្គាល់ខាងលើរួចមកហើយ តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាថាតើ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខជំទាស់នឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុញ្ញាតឲ្យមានសេចក្តីសម្រេច “វែង” ឬទេ[50] ហើយថាតើ វាពាក់ព័ន្ធនឹងកាលៈទេសដើម្បីធ្វើយុត្តិកម្មចំពោះការពន្យាពេលឬទេ។ ពុំមានចំណុចណាមួយនៅក្នុងសេចក្តីសម្រេចលើបណ្តឹងសាទុក្ខជំទាស់នឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលអនុញ្ញាតឲ្យមានសេចក្តីសម្រេចវែងទេ។ បើតាមឧទាហរណ៍ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង *Mladić* មានចំនួនត្រឹមតែ ១៥ ទំព័រ និងត្រូវបានចេញនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ អនុលោមតាមសំណើរបស់រដ្ឋអាជ្ញានៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១១[51]។ ឧទាហរណ៍ពី*រឿងក្តី* *Mladić* បង្ហាញថា សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលស្មុគស្មាញនៅតុលាការព្រហ្មទណ្ឌអន្តរជាតិអាចធ្វើជាសង្ខេប មានសម្អាងហេតុពេញលេញ និងត្រូវចេញទៅតាមលក្ខណៈមួយដែលមិនអូសបន្លាយកិច្ចដំណើរការនីតិវិធីបំបែកដំណើរការនីតិវិធីឲ្យលើសពីថិរវេលា ២ ខែទៅតាមប្រក្រតីទិនទេ។ មកទល់នឹងពេលនេះ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង00២ ចាប់ផ្តើមនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ហើយនៅតែមិនទាន់ដោះស្រាយរួចទៀត បន្ទាប់ពីរយៈពេល ១ឆ្នាំ ៧ខែ បានកន្លងផុតទៅហើយក្តី។

## **ខ. ការខកខានក្នុងការផ្តល់សម្អាងហេតុជាលាយលក្ខណ៍អក្សរ បង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរនៅក្នុងកាលៈទេសៈនានា**

### (I) **អង្គហេតុនានាដែលពាក់ព័ន្ធ**

២២. វាមានរយៈពេលជាងពីរខែកន្លះហើយ គិតចាប់តាំងពីអង្គជំនុំជម្រះនេះបានប្រកាសជាសាធារណៈនូវសាលដីកាលើបណ្តឹងឧទ្ធរណ៍អំពីការបំបែកកិច្ចដំណើរការនីតិវិធី នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣។

---

49 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង µdouard Karemera*, សំណុំរឿងលេខ ICTR-98-44-AR73.1, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Mathieu Ngirumpatse ដែលជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចេញថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២00៨ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ថ្ងៃទី ៣0 ខែ មករា ឆ្នាំ ២00៩ ត្រង់កថាខណ្ឌ ១៩ ។

50 សូមមើលកថាខណ្ឌ ២៤ ខាងលើ។

51 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ratko Mladić*, សេចក្តីសម្រេចលើសំណើរួមរបស់អយ្យការដែលសុំបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីដំណើរការសវនាការដាច់ពីគ្នា និងសុំកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ, សំណុំរឿងលេខ IT-09-92-PT (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១។

វាមានរយៈពេលជាង ២១ថ្ងៃហើយ គិតចាប់តាំងអង្គជំនុំជម្រះសាលាដំបូងបានប្រកាសអំពីសេចក្ដីសម្រេចធ្វើឡើងដោយផ្ទាល់មាត់លើការបំបែកកិច្ចដំណើរការនីតិវិធី នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣។ សវនាការសម្រាប់សំណុំរឿង ០០២/០១ បានបន្តទៅមុខទៀត ប៉ុន្តែដំណើរការពាក់ព័ន្ធតែនឹងការចោទប្រកាន់ផ្នែកអង្គហេតុដែលបានកំណត់នៅក្នុងសេចក្ដីសម្រេចតែប៉ុណ្ណោះ។ ដោយហេតុថា វិសាលភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីមានលក្ខណៈស្រដៀងគ្នាទៅនឹង វិសាលភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីចាប់ពីខែកញ្ញា ឆ្នាំ២០១១ មក សេចក្ដីថ្លែងការណ៍ ផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូងបង្ហាញថា សវនាការនៅក្នុងសំណុំរឿង ០០២/០១ នាពេលនេះ កំពុងធ្វើការបញ្ចប់យ៉ាងឆាប់រហ័ស។ នៅក្នុងអនុស្សរណៈចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងលើកឡើងថា៖

> *"ខណៈពេលដែលចេញសាលដីកាលើបណ្ដឹងឧទ្ធរណ៍ស្ដីពីកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងកំពុងតែជិតនឹងឈានដល់ការបញ្ចប់សំណុំរឿង ០០២/០១។ មានការប៉ាន់ប្រមាណថា មានតម្រូវការចំនួនថ្ងៃសវនាការបន្តិចបន្តួចថែមទៀត ជាមួយនឹងវត្តមានជនជាប់ចោទទាំងបីនាក់ (សេចក្ដីបញ្ជាក់បន្ថែម) ដើម្បីបញ្ចប់សវនាការលើភស្តុតាងនៅក្នុងការជំនុំជម្រះលើកដំបូង"*[52]។

## (II) ច្បាប់ដែលពាក់ព័ន្ធ

២៣. ការខកខានមិនបានផ្ដល់សម្អាងហេតុជាលាយលក្ខណ៍អក្សរនៅក្នុងពេលវេលាសមស្រប មានផលវិបាកធ្ងន់ធ្ងរជាច្រើន សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ១០៤ នៃវិធានផ្ទៃក្នុង។ នៅក្នុងឆ្នាំ២០១១ ដោយបានទទួលសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងបានសម្រេចតាមច្បាប់ជាធរមានស្ដីពីការពន្យារពេលនៅក្នុងការផ្ដល់នូវសម្អាងហេតុជាលាយលក្ខណ៍អក្សរ ដោយយល់ឃើញថា ការពន្យារពេលមួយខែ នៅក្នុងការផ្ដល់សម្អាងហេតុជាលាយលក្ខណ៍អក្សរ ធ្វើឡើងដោយអង្គបុរេជំនុំជម្រះ គឺជា "វិការៈផ្នែកនីតិវិធី ដែលជាបឋមបានប៉ះពាល់ដល់សុវត្ថិភាពគតិយុត្តិ និងសច្ចភាពផ្លូវច្បាប់នៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌"[53] ដោយកម្រិតឱកាសក្នុងការរៀបចំការធ្វើសេចក្ដីសន្និដ្ឋានស្ដីពីការបន្តការឃុំខ្លួនបណ្ដោះអាសន្ន[54]។

---

[52] ឯកសារលេខ E163/5/1/13/1 អនុស្សរណៈផ្ញើជូនភាគីនានា ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៣ (iii)។

[53] ឯកសារលេខ E50 សេចក្ដីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៩។

[54] ឯកសារលេខ E50 កថាខណ្ឌ ២៥ ដល់ ២៧។

២៤. នៅក្នុងរឿងក្តី *Hadjianastassiou* (ឆ្នាំ ១៩៩២)[55] តុលាការស្តីពីសិទ្ធិមនុស្សអឺរ៉ុបបានធ្វើការពិចារណាលើការរំលោភជាសក្តានុពលលើការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលកើតចេញមកពីការខកខានមិនបានផ្តល់សម្អាងហេតុជាលាយលក្ខណ៍អក្សរណាមួយ រហូតដល់រយៈពេល ៤៩ថ្ងៃ បន្ទាប់ពីចេញសេចក្តីសម្រេចផ្ទាល់មាត់រួច ដោយបដិសេធទាំងស្រុងនឹងអ្នកដាក់ពាក្យសុំនូវលទ្ធភាពក្នុងការរៀបចំនូវបណ្តឹងឧទ្ធរណ៍លើចំណុចអង្គច្បាប់។ តុលាការបានបញ្ជាក់ថា: "តុលាការជាតិត្រូវតែ [...] បង្ហាញដោយមានសច្ចភាពគ្រប់គ្រាន់នូវមូលដ្ឋាននានាដែលជាបង្អែកក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន។ បញ្ហានេះហើយ ក្នុងចំណោមនោះ ដែលធ្វើឱ្យជនជាប់ចោទមានលទ្ធភាព ក្នុងការអនុវត្តប្រកបដោយផលប្រយោជន៍នូវសិទ្ធិនានាក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ដែលមានចំពោះរូបគាត់"[56]។

២៥. ការខកខានក្នុងការផ្តល់សម្អាងហេតុជាលាយលក្ខណ៍អក្សរនៅក្នុងពេលវេលាសមស្រប ក៏បានធ្វើឱ្យប៉ះពាល់ផងដែរដល់សេចក្តីទុកចិត្តរបស់សាធារណជន លើកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Hong Kong SAR* តទល់នឹង *Tin's Label Factory Ltd*[57] តុលាការទីក្រុងហុងកុងសម្រាប់បណ្តឹងសាទុក្ខចុងក្រោយ៖

> *បានលើកឡើងជាថ្មីម្តងទៀត និងបានបញ្ជាក់បន្ថែមយ៉ាងម៉ឺងម៉ាត់ថា ចៅក្រមនៅគ្រប់ជាន់ថ្នាក់ទាំងអស់មានភារកិច្ចចេញសេចក្តីសម្រេចនានានៅក្នុងរយៈពេលមួយសមស្រប បន្ទាប់ពីបញ្ចប់សវនាការរួច។ នៅពេលដែលសេចក្តីសម្រេចធ្វើឡើងផ្ទាល់មាត់ត្រូវបានផ្តល់លទ្ធផលដោយមានសម្អាងហេតុដែលត្រូវចេញនៅពេលបន្ទាប់ វាជាភារកិច្ចរបស់ចៅក្រមក្នុងការផ្តល់នូវសម្អាងហេតុ នៅក្នុងរយៈពេលមួយសមស្រប។ ចំណុចនេះមិនត្រឹមតែមានសារៈសំខាន់ចំពោះភាគីនានាប៉ុណ្ណោះទេ តែថែមទាំងសំខាន់ចំពោះការរក្សានូវសេចក្តីទុកចិត្តរបស់សាធារណជនលើកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះផងដែរ*[58]។

២៦. ស្រដៀងគ្នានេះដែរ ការអត្ថាធិប្បាយរបស់វិធាន ២.១២(ខ) នៃក្រមសីលធម៌គំរូសម្រាប់មន្ត្រីតុលាការ របស់គណៈមេធាវីសហរដ្ឋអាមេរិក បានចែងថា៖ "សេចក្តីទុកចិត្តរបស់សាធារណជនទៅលើប្រព័ន្ធតុលាការ គឺផ្អែកលើភាពយុត្តិធម៌ទាន់ពេលវេលា។ ដើម្បីលើកតម្កើងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះប្រកបដោយប្រសិទ្ធភាព ចៅក្រមអមដោយអាជ្ញាធរគ្រប់គ្រងត្រូវចាត់វិធានការ

---

[55] រឿងក្តី *Hadjianastassiou* តទល់នឹង ប្រទេសក្រិច ពាក្យសុំលេខ ១២៩៤៥/៨៧, សាលក្រម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩២ (ECtHR) ត្រង់កថាខណ្ឌ ៣៣។

[56] *ដូចខាងលើ*។

[57] រឿងក្តី *Hong Kong SAR* តទល់នឹង *Tin's Label Factory Ltd* (ឆ្នាំ ២០០៩) ផ្នែក ៩ សំណុំរឿងលេខ ៨ [CFA] ត្រង់កថាខណ្ឌ ១២។

[58] *ដូចខាងលើ*។

នានា តាមតម្រូវការដើម្បីធានាថា ចៅក្រមទាំងឡាយដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន មានការគ្រប់គ្រងចំនួនការងាររបស់ពួកខ្លួនបានឆាប់រហ័ស”[59]។

(III) **ទទ្ធីករណ៍**

២៧. អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនថា ការចោទប្រកាន់តែមួយគត់ពាក់ព័ន្ធទៅនឹង “ការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី១ និងទី២ ទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ”[60] អាចដំណើរការទៅមុខបាន។ ភាពស្មុគស្មាញនៃសេចក្តីសម្រេចនេះ គឺថាដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទប្រកាន់ខ្លះ ក្នុងសំណុំរឿង00២ នឹងត្រូវបញ្ចប់ដោយប្រសិទ្ធភាព។ ហេតុដូច្នេះ វិធាន១០៤(៤)(ក) នឹងអនុញ្ញាតឱ្យមានបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះផងដែរ។ សហព្រះរាជអាជ្ញាបានកំពុងរង់ចាំសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនេះនៅមុនពេលពិចារណាថាតើបណ្តឹងសាទុក្ខបន្ថែម គឺជាការចាំបាច់ដែរឬយ៉ាងណា ប៉ុន្តែដោយហេតុថាពេលវេលានោះបានអូសបន្លាយ ហើយសវនាការជំនុំជម្រះបានបោះជំហានទៅមុខ ផលប្រយោជន៍របស់សហ-ព្រះរាជអាជ្ញានៅលើផ្នែកសច្ចភាពគតិយុត្តិ និងសេចក្តីសម្រេចដែលមានសំអាងហេតុ ក៏បានរងការប៉ះពាល់ដែរ។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាកំពុងរក្សាទុកកាលបរិច្ឆេទ ដែលសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរស្តាពរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីអាចចេញ មានភាព “ពុំជាក់លាក់ និងបើកចំហរសម្រាប់ការកែប្រែ”[61] ហើយដូច្នេះទើបបណ្តឹងសាទុក្ខនេះគឺជាបណ្តឹងដែលធ្វើទាន់ពេលវេលាដោយអនុលោមតាមវិធាន១០៧(១)។

២៨. ជាទូទៅ ជាមួយសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បានបំបែកសំណុំរឿង 00២ ដោយពុំបានផ្តល់សម្អាងហេតុសោះឡើយ។ ដូចពេលមុនដែរ នាពេលបច្ចុប្បន្ន “អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ព័ត៌មានជាក់លាក់ ឬច្បាស់លាស់ណាមួយអំពីចំនួន វិសាលភាព ឬថិរវេលានៃការជំនុំជម្រះតាមការប៉ាន់ប្រមាណ ក្រោយសំណុំរឿង 00២/0១”[62]។ បើទោះបីជាកិច្ចដំណើរការនីតិវិធីសវនាការនាពេលនេះបានបន្ត[63] ដោយផ្អែកទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[64] ដែលសម្អាងទៅតាម “បទដ្ឋានមិនបង្ហាញច្បាស់លាស់”[65] ក៏ដោយ ក៏អង្គជំនុំជម្រះសាលា

[59] ក្រមគំរូស្តីពីដំណើរការរបស់តុលាការ របស់គណៈមេធាវីអាមេរិក (ឆ្នាំ ២០១១) វិធាន ២.១២ (សហរដ្ឋអាមេរិក)។

[60] ឯកសារ **E1/176.1** ប្រតិចារឹក, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ត្រង់ទំព័រ ៤ បន្ទាត់ ១៣-១៧។

[61] ឯកសារ**E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី, *ដូចជើងទំព័រ៤* ត្រង់កថាខណ្ឌ ១៧។

[62] ឯកសារ **E163/5/1/13** *ដូចឯកសារយោងខាងលើ ត្រង់កថាខណ្ឌ ២៣*។

[63] ឯកសារ **E1/176.1** ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ១ បន្ទាត់ ១៨-២១។

[64] ឯកសារ **E1/176.1** *ដូចឯកសារយោងខាងលើ* ត្រង់ទំព័រ ៤ បន្ទាត់ ១៣-១៧។

[65] ឯកសារ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី, *ដូចជើងទំព័រ ៤* ត្រង់កថាខណ្ឌ ៤៥។

ដំបូងពុំបានផ្តល់ "ផែនការច្បាស់លាស់ ឬផ្តល់ព័ត៌មានណាមួយមកទល់នឹងពេលនេះ ទាក់ទិននឹងសំណុំរឿងបន្តបន្ទាប់ដែលត្រូវជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២"[66] ឬពុំបានបញ្ជាក់ច្បាស់លាស់ថាតើ "ការតំណាងសមហេតុផល" គឺជាគោលដៅនៃសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួនដែរឬយ៉ាងណាឡើយ[67]។ ស្ថានភាពនេះនៅតែជាការពិត បើទោះបីជាមានការបញ្ជាក់ របស់អង្គជំនុំជម្រះសាលាដំបូងដែលថាសេចក្តីសម្រេច ជាលាយលក្ខណ៍អក្សរនឹងត្រូវបានផ្តល់ "ឆាប់ៗតាមដែលអាចធ្វើទៅបាន"[68] និងអំណះអំណាងជំនួសមុខឲ្យអង្គជំនុំជម្រះសាលាដំបូងដែលថាសេចក្តីសម្រេចដែលមានសម្អាងហេតុនឹងមាន "ឆាប់ៗតាមដែលអាចធ្វើទៅបាន [ដោយហេតុថា] ហើយតាមការបង្គាប់របស់ អ.ជ.ត.ក សេចក្តីសម្រេចនេះជាសេចក្តីសម្រេចវែង" (ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣);[69] ហើយ "វានឹងមិនយូរជាងនេះទៀតខ្លាំងពេកឡើយ" (ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣)[70]។

២៩. ដោយពេលវេលាកន្លងផុតពីមួយថ្ងៃទៅមួយថ្ងៃ សហព្រះរាជអាជ្ញា និងភាគីផ្សេងៗបន្តរងការបាត់បង់ឱកាសក្នុងការវាយតម្លៃអំពីជំហរគតិយុត្តរបស់ពួកខ្លួន ទាក់ទងនឹងសេចក្តីសម្រេចនេះ និងការវាយតម្លៃអំពីលទ្ធភាពនៃជោគជ័យនៃបណ្តឹងសាទុក្ខណាមួយដែលអាចមាន និងការរៀបចំវិសាលភាពជាក់លាក់នៃសេចក្តីសន្និដ្ឋានបញ្ចប់សវនាការរបស់ពួកខ្លួន។

៣០. សំខាន់បំផុត ដោយពិចារណាទៅលើរយៈពេលដ៏ខ្លី ដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ប្រាប់ថា សវនាការនេះនឹងត្រូវបានបញ្ចប់ ហើយរយៈពេលកំណត់បីខែ ដែលអង្គជំនុំជម្រះត្រូវតែចេញសេចក្តីសម្រេចរបស់ខ្លួននោះ បណ្តឹងសាទុក្ខណាដែលភាគីបានដាក់ មានឱកាសតិចតួចដែលត្រូវយកមកអនុវត្ត ប្រសិនបើការដាក់បណ្តឹងសាទុក្ខនោះទទួលបានជោគជ័យ។ ប្រសិនបើហេតុផលសម្រាប់សេចក្តីសម្រេចលើដីកាបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ ត្រូវបានដាក់នៅថ្ងៃនេះ ហើយភាគីបានប្តឹងសាទុក្ខ និងដោយសន្មតថាអង្គជំនុំជម្រះបានចំណាយពេលបីខែក្នុងការចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខនោះ សវនាការនឹងចប់ជាធរមាន។ ការអនុវត្តសេចក្តីសម្រេចនេះ នឹងមានការពិបាកយ៉ាងខ្លាំង ប្រសិនបើវាផ្ទុយពីទស្សនៈរបស់អង្គជំនុំជម្រះសាលាដំបូង ដូច្នេះទំនងជាមានលទ្ធភាពតិចតួចណាស់។

---

[66] ឯកសារ E163/5/1/13 *ដូចឯកសារយោងខាងលើ* ត្រង់កថាខណ្ឌ ២៤។

[67] ឯកសារ E163/5/1/13 *ដូចឯកសារយោងខាងលើ* ត្រង់កថាខណ្ឌ ៥០។

[68] ឯកសារ E1/176.1 ប្រតិចារឹក, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ត្រង់ទំព័រ ១ បន្ទាត់ ២៣-២៤, សូមមើលផងដែរ E163/5/1/13 សេចក្តីសម្រេចលើបណ្តឹងទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី, *ដូចជើងទំព័រ ៤* ត្រង់កថាខណ្ឌ ៤៦។

[69] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើទៅភាគី ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣។

[70] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើទៅភាគី ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣។

## គ. សេចក្តីបង្គាប់បន្ទាន់មួយគឺជាដំណោះស្រាយសមស្របបំផុតនៅក្នុងកាលៈទេសៈបែបនេះ

៣១. នៅក្នុងកាលៈទេសៈបែបនេះ ដំណោះស្រាយដែលបានស្នើសុំឲ្យមានសេចក្តីបង្គាប់បន្ទាន់មួយទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីផ្តល់នូវសម្អាងហេតុជាលាយលក្ខណ៍អក្សរដោយមិនពន្យារពេលនោះ គឺជាមធ្យោបាយដែលមានលក្ខណៈជ្រៀតជ្រែកតិចតួច និងដោយផ្ទាល់បំផុត ដែលអាចប្រើប្រាស់បានដើម្បីដោះស្រាយដោយផ្ទាល់ចំពោះផលប៉ះពាល់ដល់សហព្រះរាជអាជ្ញា។ ដោយសារតែពេលវេលាខ្លី សហព្រះរាជអាជ្ញាស្នើសុំបន្ថែមទៀត ឲ្យមានការបង្គាប់ទៅអង្គជំនុំជម្រះសាលាដំបូងផ្តល់នូវសម្អាងហេតុជាលាយលក្ខណ៍អក្សរជាភាសាផ្លូវការមួយរបស់ អ.វ.ត.ក ដោយរង់ចាំការបកប្រែជាពីរភាសាទៀត។ ប្រការនេះ គឺជាការអនុវត្តពិសេសដែលសមហេតុផលនៅក្នុងកាលៈទេសៈនៃភាពបន្ទាន់បំផុតដែលកើតឡើងដោយសារ ការពន្យារពេលក្នុងការផ្តល់សម្អាងហេតុជាលាយលក្ខណ៍អក្សរនោះ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានចេញសេចក្តីសម្រេចរបស់ខ្លួនជាភាសាផ្លូវការមួយ ជា “សំណៅចម្លងដែលបានប្រគល់ជូនជាមុនដើម្បីជាការគួរសម” ដោយរង់ចាំការដាក់សំណៅបកប្រែជាពីរភាសាផ្លូវការទៀតនៅពេលក្រោយ[71]។

## V. **សំណើសុំ**

៣២. យោងទៅលើហេតុផលទាំងនេះ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល **ទទួលយក និងពិចារណា** លើសំណើនេះជាបញ្ហាបន្ទាន់បំផុត និងបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់នូវសម្អាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សេចក្តីសម្រេច ជាភាសាផ្លូវការមួយរបស់ អ.វ.ត.ក ដោយរង់ចាំការបកប្រែជាពីរភាសាទៀត ដោយពុំពន្យារពេលទៀតឡើយ ប្រសិនបើចាំបាច់។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |

[71] សូមមើល ឧទាហរណ៍ សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើជូនភាគីនានា ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ (ផ្សព្វផ្សាយ ជាឯកសារ E172 ដែលត្រូវបានជូនដំណឹងក្រោយទៀតនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២)។ សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើជូនភាគីនានា ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ (ផ្សព្វផ្សាយ ជាឯកសារ E216/3 ដែលត្រូវបានជូនដំណឹងក្រោយទៀតនៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២)។ សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើជូនភាគីនានា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ (ផ្សព្វផ្សាយ ជាឯកសារ E233 ដែលត្រូវបានជូនដំណឹងក្រោយទៀតនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២)។